នស/រកត/០១០៨/០៧៨

# ព្រះរាជក្រឹត្យ

## ស្តីពីវិសោធនកម្មមាត្រា ៨, ៩ និង ១១ នៃជំពូកទី ៤ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៨០១/២៦៤ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០១ ស្តីពីនីតិសារជាតិ នៃមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រតនខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/ ០៧០៤ /១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ /នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដាឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស /រកត / ១២៩៧ /៩១ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តិនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥៩៩/០៣ ចុះថ្ងៃទី ២៨ ខែឧសភា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការហាមប្រាម ការប្រើប្រាស់គ្រាប់មីនគ្រប់ប្រភេទប្រឆាំងមនុស្ស
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០០/១៦០ ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការបង្កើតអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកត/០៨០១/២៦៤ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០១ ស្តីពីនីតិសារជាតិ នៃមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា មួយ.-**

ត្រូវបានកែសំរួលមាត្រា ៨, ៩ និងមាត្រា ១១ នៃជំពូកទី ៤ នៃព្រះរាជក្រឹត្យលេខ នស/រកត/ ០៨០១/២៦៤ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០១ ស្តីពីនីតិសារជាតិនៃមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា ដូចតទៅ :

ROYAUME DU CAMBODGE ... ROYAL

### ជំពូកទី ៤
### ក្រុមប្រឹក្សាភិបាល

**មាត្រា ៨.- ថ្មី**

ក្រុមប្រឹក្សាភិបាល ម.ស.ម.ក. មានសមាជិក ៨រូប ។ សមាជិកក្រុមប្រឹក្សាភិបាល ត្រូវបានតែងតាំងឡើងដោយព្រះរាជក្រឹត្យ តាមសំណើរបស់រាជរដ្ឋាភិបាល ។

**មាត្រា ៩.- ថ្មី**

ក្រុមប្រឹក្សាភិបាលត្រូវមានប្រធានមួយ (១)រូប អនុប្រធានមួយ (១)រូប អនុប្រធានអចិន្ត្រៃយ៍មួយ (១) រូប និងសមាជិកប្រាំ (៥)រូប ។ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានជាស្វ័យប្រវត្តិជាប្រធាននៃក្រុមប្រឹក្សាភិបាល ។ ក្នុងករណីដែលនាយករដ្ឋមន្ត្រី មិនអាចបំពេញមុខនាទីនេះដោយផ្ទាល់បាន នាយករដ្ឋមន្ត្រីអាចទូលស្នើព្រះមហាក្សត្រ សុំតែងតាំងឥស្សរជនមួយរូបជាប្រធាននៃក្រុមប្រឹក្សាភិបាលផ្ទេរសិទ្ធិ ។

ប្រធានក្រុមប្រឹក្សាភិបាលផ្ទេរសិទ្ធិ ជាតំណាង ម.ស.ម.ក.។

**មាត្រា ១១.- ថ្មី**

ក្នុងករណីប្រធានក្រុមប្រឹក្សាភិបាលផ្ទេរសិទ្ធិអវត្តមាន អនុប្រធានអចិន្ត្រៃយ៍ត្រូវទទួលបន្ទុកជាប្រធានក្រុមប្រឹក្សាភិបាលផ្ទេរសិទ្ធិស្តីទី ។

**មាត្រា ពីរ.-**

នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា បី.-**

ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីពេលឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៨*

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧.០៨០១.០៨១

*បានយកសេចក្តីក្រាបបង្គំទូលថ្វាយ*

*សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ*

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខ : ១៤.ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ... ឆ្នាំ២០០៨
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

ស៊ុន ចិនកេន